អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**


- ពន្ធលើប្រាក់ចំណេញពីការលក់ ឬផ្ទេរមូលធននឹងចូលជាធរមាន នៅខែមករា ឆ្នាំ ២០២២
- កម្ពុជា ស្ថិតក្នុងលំដាប់លេខ២នៃការវិនិយោគនៅក្រៅប្រទេសវៀតណាម
- ឥណ្ឌាសហការជាមួយរដ្ឋបាលខេត្តកែប ដើម្បីអភិវឌ្ឍន៍វិស័យទេសចរណ៍ និងកសិកម្ម
- កម្ពុជាទទួលបានថវិកា ៣៣៩លានដុល្លារ ពីកម្មវិធីជំនួយពាណិជ្ជកម្ម ដើម្បីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម
- អ្នកនាំចេញកៅស៊ូកម្ពុជា រំពឹងថា តំបន់អតីតសហភាពសូវៀត នឹងជួយពង្រីកទីផ្សារនាំចេញពេលអនាគត
- លទ្ធផលសិក្សាស្រាវជ្រាវបង្ហាញថា ផលិតផលកសិកម្មកម្ពុជា ៩មុខ មានតម្លៃខ្ពស់លើទីផ្សារ
- កម្ពុជាសង្ឃឹមថា ជើងហោះហើរផ្ទាល់ជាមួយជប៉ុននឹងចាប់ផ្ដើមឡើងវិញឆាប់ៗ
- រដ្ឋមន្ត្រីកសិកម្ម ណែនាំឱ្យកសិករ ចិញ្ចឹមត្រីអណ្តែង និងកង្កែបរួមគ្នា ចងក្រង ជាបណ្តុំអាជីវកម្ម
- អតិរេកពាណិជ្ជកម្មឥណ្ឌូណេស៊ី សម្រាប់ខែកក្កដា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)
- ឱនភាពពាណិជ្ជកម្មវៀតណាម ពាក់កណ្តាលខែដំបូង នៃខែកក្កដា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)
- អតិផរណា នៅប្រទេសហ្វីលីពីនទំនងជាមានភាពលើសពីគោលដៅ ដែលរដ្ឋាភិបាលកំណត់ម្តងទៀតនៅខែសីហា
- តម្លៃប្រេងឆៅធ្លាក់ចុះ ខណៈរោងចក្រចម្រាញ់ប្រេងអាមេរិកបិទទ្វារ ដោយសារខូចខាតពីព្យុះសង្ឃរា Ida
- អតិផរណានៅបារាំង កើនឡើងក្នុងខែសីហា ឆ្នាំ២០២១ ដែលជាកម្រិតខ្ពស់បំផុត ៣ឆ្នាំចុងក្រោយ



ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា — អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី — ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ — អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា　　សប្តាហ៍ទី១ ខែកញ្ញា ឆ្នាំ២០២១　　លេខ ៖ ៨៣

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ពន្ធលើប្រាក់ចំណេញពីការលក់ ឬផ្ទេរមូលធននឹងចូលជាធរមាន នៅខែមករា ឆ្នាំ ២០២២



*ប្រភព៖ Michael Firn, Khmer Times ២០២១*

ពន្ធលើប្រាក់ចំណេញ ពីការលក់ ឬផ្ទេរមូលធន នឹងចូលជាធរមាន ចាប់ពីថ្ងៃទី១ ខែមករាឆ្នាំក្រោយ ក្នុងអត្រាពន្ធ ២០% ទៅលើបុគ្គលទាំងឡាយដែលលក់មូលធនសកម្ម ដូចជា អចលនទ្រព្យ ការជួល និងការកាន់កាប់ហិរញ្ញវត្ថុ នេះបើយោងតាមសេចក្តីជូនដំណឹងរបស់នាយកដ្ឋានពន្ធលើអចលនទ្រព្យ និងទ្រព្យសម្បត្តិ នៃអគ្គនាយកដ្ឋានពន្ធដារ(GDT)នៃប្រទេសកម្ពុជា។

ច្បាប់បានពង្រីកវិសាលភាពលើការកំណត់ពន្ធលើប្រាក់ចំណេញ(CGT) ដល់បុគ្គលហើយត្រូវបានណែនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាលពីខែមេសាឆ្នាំមុន ហើយគ្រោងនឹងចូលជាធរមានបីខែបន្ទាប់។ ប៉ុន្តែ រាជរដ្ឋាភិបាល បានសម្រេចចិត្តពន្យាពេលបង់ពន្ធរហូតដល់ខែមករាឆ្នាំនេះ ដោយសារតែតម្រូវការអចលនទ្រព្យ រងផលប៉ះពាល់ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ច និងការរីករាលដាលនៃមេរោគកូវីដ១៩។ នៅពេលដែលស្ថានភាពជំងឺកូវីដ១៩ នៅបន្តរីករាលដាលក្នុងប្រទេសកម្ពុជាបន្ទាប់ពីឧប្បត្តិហេតុឆ្លងជាសហគមន៍ថ្ងៃទី ២០ ខែកុម្ភៈឆ្នាំនេះ រាជរដ្ឋាភិបាលបានពន្យារពេលបង់ពន្ធរយៈពេលមួយឆ្នាំទៀត។

ទន្ទឹមនឹងនេះ យោងតាមប្រកាស ឬ ច្បាប់ ដែលបានដាក់ឱ្យអនុវត្តនៅថ្ងៃទី១ ខែមេសា ឆ្នាំមុនដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី វិសាលភាពពន្ធលើប្រាក់ចំណេញពីការលក់ ឬផ្ទេរទ្រព្យសកម្ម អនុវត្តចំពោះទាំងនិវាសនជន និងអនិវាសនជនក្នុងអត្រា ២០% នៃប្រាក់ចំណេញដែលបានមកពី ការលក់ ឬផ្ទេរមូលធន ៦ ប្រភេទ៖ អចលនវត្ថុ ឬ ដីធ្លី, អគារ និងសំណង់ផ្សេងៗ ការជួល, ការវិនិយោគទ្រព្យសកម្មដូចជាភាគហ៊ុននិងប័ណ្ណបំណុល, ពាណិជ្ជនាម ដូចជា អាជីវកម្ម ឬម៉ាកយីហោ, កម្មសិទ្ធិបញ្ញា និងរូបិយប័ណ្ណបរទេស។ *ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០២១*

## កម្ពុជា ស្ថិតក្នុងលំដាប់លេខ២ នៃការវិនិយោគនៅក្រៅប្រទេស របស់ប្រទេសវៀតណាម



*ប្រភព៖ VNA, Khmer Times ២០២១*

យោងតាមក្រសួងផែនការ និងវិនិយោគ ប្រទេសវៀតណាម បានឱ្យដឹងថា ការវិនិយោគនៅក្រៅប្រទេសរបស់វៀតណាម ទៅកាន់ប្រទេស និងដែនដី ចំនួន២០បានកើនឡើង ៧៤,១% ក្នុងចំនួនរហូតដល់ ៥៧៥លានដុល្លារ ត្រូវបានបញ្ជូន ក្នុងរយៈពេល ៨ ខែដំបូងនៃឆ្នាំ ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ក្នុងនោះ កម្ពុជា ស្ថិតនៅលំដាប់ទី២ ក្នុងការទទួលបានការវិនិយោគថ្មី ចំនួន ៨៩.៤ លានដុល្លារ ពីវៀតណាម ខណៈសហរដ្ឋអាមេរិកដែលជាគោលដៅទទួលបានបានការវិនិយោគខ្ពស់ជាងគេ ដែលមានចំនួន ៣០២.៨ លានដុល្លារស្មើនឹង ៥២,៧%នៃចំនួនសរុប។ ដោយឡែកឡាវ និង កាណាដា ទទួលបាន ៤៧,៨ លានដុល្លារ និង ៣២,១ លានដុល្លារ រៀងគ្នាៗ។

ទន្ទឹមនឹងនេះ គិតត្រឹមថ្ងៃទី ២០ ខែសីហា វៀតណាមមានគម្រោងវិនិយោគ នៅក្រៅប្រទេសដែលនៅមានសុពលភាព ចំនួន ១,៤២៨គម្រោង ដែលភាគច្រើនមាន (៣៦,៣%) ដំណើរការនៅក្នុងឧស្សាហកម្មរ៉ែ និង ១៥,៣% នៅក្នុងវិស័យកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ យោងតាម ទីភ្នាក់ងារវិនិយោគបរទេសរបស់ក្រសួង បង្ហាញថា ប្រទេសឡាវ ទទួលការវិនិយោគវៀតណាមច្រើនជាងគេ ដោយមាន២៣,៨% កម្ពុជា ១៣,១% និងរុស្ស៊ី១២,៩%។ *ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ Khmer Times ចេញផ្សាយថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១*

## ឥណ្ឌាសហការជាមួយរដ្ឋបាលខេត្តកែប ដើម្បីអភិវឌ្ឍវិស័យទេសចរណ៍ និងកសិកម្ម



*រូបភាព ៖ ហ៊ាន រង្សី*

បច្ចុប្បន្នខេត្តកែប មានឆ្នេរសមុទ្រ ដែលមានប្រវែង ៣៥០ ម៉ែត្រ ហើយមានកោះចំនួន ១២ និងថ្មប៉ប្រះទឹក។ ថ្មីៗនេះ រាជរដ្ឋាភិបាលបានសម្រេចអនុវត្តគម្រោងកែលម្អឆ្នេរភក់ទៅជាឆ្នេរខ្សាច់កម្សាន្តកម្រិតខ្ពស់ប្រវែង ២ ៧០០ម៉ែត្រ ដើម្បីទាក់ទាញភ្ញៀវទេសចរ។ គម្រោងនេះនឹងអនុវត្តចាប់ពីផ្សារក្តាម ទៅដល់ព្រៃកោងកាង ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប។ ភាគីឥណ្ឌា បានមកស្វែងយល់ពីសក្តានុពលរបស់ខេត្តកែបដែលជាតំបន់សក្តានុពលទេសចរណ៍ឆ្នេរសមុទ្រ ដោយសិក្សាទៅលើវិស័យទេសចរណ៍ កសិកម្ម និង អប់រំ ជាដើម។

នៅក្នុងជំនួបរវាងអភិបាលខេត្តកែប និងឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំកម្ពុជា ភាគីទាំងពីរ បានឯកភាពរួមគ្នាប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ និងកសិកម្មនៅខេត្តកែប ដែលជាតំបន់សក្តានុពលទេសចរណ៍ឆ្នេរសមុទ្រ។ ភាគីទាំងពីរ បានឯកភាពធ្វើការរួមគ្នា ពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យទេសចរណ៍ កសិកម្ម និងការកសាងសមត្ថភាពដើម្បីបង្កើនឱកាសសេដ្ឋកិច្ចអតិបរមា។

អភិបាលខេត្តកែប បានលើកឡើងពីសក្តានុពលសំខាន់ៗ និងបង្ហាញពីចក្ខុវិស័យអភិវឌ្ឍ ហើយសង្ឃឹមថាឥណ្ឌានឹងពិនិត្យរាល់គម្រោងជួយគាំទ្រ ពិសេសគម្រោងអភិវឌ្ឍន៍លើវិស័យទាំង ៣ ខាងលើ។

របាយការណ៍ក្រសួងពាណិជ្ជកម្មកម្ពុជាឱ្យដឹងថា ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ឥណ្ឌា ឆ្នាំ ២០២០ មានតម្លៃ ១៩០,១៣ លានដុល្លារ ធ្លាក់ចុះ ២៥,៨១ភាគរយធៀបឆ្នាំ ២០១៩។ ក្នុងនោះការនាំចេញពីកម្ពុជាមានតម្លៃ ៦១,៣៦ លានដុល្លារ ធ្លាក់ចុះ ៥,១២ភាគរយ និងនាំចូលមាន ១២៨,៧៧ លានដុល្លារ ធ្លាក់ចុះ ៣២,៧៩ភាគរយ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ភ្នំពេញបុស្តិ៍ ចេញផ្សាយថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២១*

## កម្ពុជាទទួលបានថវិកា ៣៣៩លានដុល្លារ ពីកម្មវិធីជំនួយពាណិជ្ជកម្ម ដើម្បីអភិវឌ្ឍវិស័យពាណិជ្ជកម្ម ក្នុងរយៈពេល ៤ឆ្នាំមកនេះ




*ប្រភព ៖ SWIFT NEWS*

ក្នុងក្របខ័ណ្ឌសកលលោក ពោលគឺក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅឆ្នាំ២០០៥ សន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី០៦ នៅទីក្រុងហុងកុង បានផ្តួចផ្តើមឱ្យមាននៅកម្មវិធីជំនួយពាណិជ្ជកម្ម ដើម្បីជួយជំរុញប្រទេសដែលមានការអភិវឌ្ឍតិចតួច អាចចូលរួមទៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគីបានយ៉ាងមានប្រសិទ្ធភាព។ បើគិតត្រឹមឆ្នាំ២០១៧ ប្រទេសកម្ពុជាទទួលបានជំនួយពីកម្មវិធីជំនួយពាណិជ្ជកម្ម (Aid for Trade) ក្នុងទំហំទឹកប្រាក់ ៣៣៩លានដុល្លារ ដើម្បីអភិវឌ្ឍលើវិស័យពាណិជ្ជកម្ម។

នេះជាកាលានុវត្តភាពសម្រាប់យើង ក្នុងការស្រូបយកធនធានមកអភិវឌ្ឍប្រទេសកម្ពុជាបន្ថែមទៀត។ ប៉ុន្តែ វាក៏អាស្រ័យទៅលើភាពប៉ិនប្រសព្វនៃការរៀបចំគម្រោង និងប្រសិទ្ធភាពនៃការអនុវត្តគម្រោង ដើម្បីឱ្យមានភាពប្រទាក់ក្រឡាជាមួយវត្ថុបំណងនៃគោលដៅជំនួយអភិវឌ្ឍ ព្រោះមានប្រទេសផ្សេងទៀតដែលត្រូវការជំនួយអភិវឌ្ឍដូចគ្នា។

នាពេលកន្លងមកនេះ ក្រសួងពាណិជ្ជកម្មបានអនុវត្តនូវគម្រោងជាច្រើនរួចមកហើយរួមមាន៖ គម្រោងធ្វើឱ្យប្រសើរឡើងនូវរោងចក្រកាត់ដេរនៅកម្ពុជា (BFC) ការរៀបចំយុទ្ធសាស្ត្រពាណិជ្ជកម្ម CTIS គោលនយោបាយដំឡូងមី គោលនយោបាយស្វាយចន្ទី យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-commerce Strategy) ការកសាងសមត្ថភាពមន្ត្រី និងគម្រោងជំរុញការនាំចេញអង្ករជាដើម។ បច្ចុប្បន្ននេះ ក្រសួងពាណិជ្ជកម្មក៏កំពុងអនុវត្តគម្រោងមួយដែលមានឈ្មោះថា គម្រោងជំរុញទីផ្សារកសិកម្មខ្នាតតូច ហៅថា AIMS(Accelerating Inclusive Market from Smallholders) ដើម្បីជម្រុញចំណូលសេដ្ឋកិច្ចគ្រួសារកសិករចំនួន ៧៥ ០០០គ្រួសារឱ្យមានការកើនឡើង តាមរយៈការតភ្ជាប់រវាងផលិតកម្ម និងទីផ្សារ។ គម្រោងទាំងនេះប្រើប្រាស់ថវិកាជាតិមួយផ្នែក និងទទួលបានជំនួយអភិវឌ្ឍពីស្ថាប័នអន្តរជាតិ។

ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការក្នុងតំបន់មេគង្គ កម្ពុជាមានកិច្ចសហប្រត្តិការអន្តរជាតិដូចជា៖ មេគង្គ-ចិន មេគង្គ-អាមេរិក មេគង្គ-ឥណ្ឌា មេគង្គ-ជប៉ុន មេគង្គ-កូរ៉េ និង គម្រោង The Ayeyawady-Chao Phraya-Mekong Economic Cooperation Strategy ជាដើម។ ទន្ទឹមនឹងនេះ ក្នុងក្របខ័ណ្ឌតំបន់អាស៊ាន កម្ពុជាក៏ស្ថិតនៅក្នុងចង្កោមប្រទេស CLMV ដែលតែងតែទទួលបានការយកចិត្តទុកពីសមាជិក និងទទួលបានគម្រោងអភិវឌ្ឍពីស្ថាប័នអភិវឌ្ឍន៍ ដើម្បីជំរុញការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ព្រមទាំងកាត់បន្ថយគម្លាតអភិវឌ្ឍរវាងសមាជិកទាំង ១០ប្រទេស។

រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងខិតខំទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងស្វែងរកជំនួយពីបណ្ដាប្រទេសផ្សេងៗ តាមរយៈគម្រោងជំនួយបច្ចេកទេស និងជំនួយហិរញ្ញប្បទាន ដើម្បីស្តារឡើងវិញនូវសេដ្ឋកិច្ច៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ swiftnews ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១។*

## អ្នកនាំចេញកៅស៊ូកម្ពុជា រំពឹងថា តំបន់អតីតសហភាពសូវៀត នឹងជួយពង្រីកទីផ្សារនាំចេញនាពេលអនាគត



*ប្រភព ៖ cnc*

កម្ពុជា នឹងមានទីផ្សារនាំចេញកៅស៊ូបន្ថែមទៀត ទៅសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU)។ សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ឬសហភាពសេដ្ឋកិច្ចអឺរ៉ាស៊ី ជាទីផ្សារអតីតសហភាពសូវៀត ដែលកម្ពុជាបានចំណាយពេលចរចាចាប់តាំងពីខែឧសភា ឆ្នាំ២០១៦មកម្ល៉េះ ហើយកំពុងឈានទៅរកការសម្រេចកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយគ្នានាពេលខាងមុខនេះ។

សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ត្រូវបានបង្កើតឡើងជាផ្លូវការណ៍នៅខែមករា ឆ្នាំ ២០១៥ ដែលរួមមានប្រទេសជាសមាជិក ដូចជាសហព័ន្ធរុស្ស៊ី ប្រទេសបេលឡារូស ប្រទេសកាហ្សាក់ស្ថាន ប្រទេសគៀហ្សាក់ស្ថាន និងប្រទេសអាមេនី។ សហភាពសេដ្ឋកិច្ច អឺរ៉ាស៊ានបាន ធ្វើសមាហរណកម្មសេដ្ឋកិច្ចទីផ្សារតែមួយ ដែលមានប្រជាជនសរុបប្រមាណ ១៨៣លាននាក់។

កន្លងមកកម្ពុជាធ្លាប់បាននាំកៅស៊ូទៅសហភាពសេដ្ឋកិច្ចអឺរ៉ាស៊ីខ្លះដែរ ប៉ុន្តែក្នុងបរិមាណតិចតួចនៅឡើយ។ ដូច្នេះ ការសម្រេចកិច្ចព្រមព្រៀងនាំចេញទៅទីផ្សារប្លុកនេះ នឹងកាន់តែទូលំទូលាយបន្ថែម ជាពិសេសគ្មានរបាំងពន្ធគយ។ នេះជាជំហានមួយល្អសម្រាប់ផលិតកម្មកៅស៊ូកម្ពុជា ដែលវិនិយោគិន និងកសិករលក្ខណៈគ្រួសារ នឹងបង្កើនការដាំដុះកៅស៊ូបន្ថែមទៀត។

បច្ចុប្បន្ន កម្ពុជាបាននាំចេញកៅស៊ូលក់ទៅឱ្យឈ្មួញកណ្តាលនៅប្រទេសវៀតណាម បន្ទាប់មកពួកគេបានលក់បន្តទៅកាន់ប្រទេសផ្សេងៗទៀត។ ក្រៅពីប្រទេសវៀតណាម កម្ពុជាក៏បាននាំចេញកៅស៊ូទៅប្រទេសចិន និងតាមរយៈឈ្មួញកណ្តាលនៅម៉ាឡេស៊ី និងសិង្ហបុរីលក់ទៅកាន់ប្រទេសឥណ្ឌា កូរ៉េខាងត្បូង និងអ៊ីតាលីផងដែរ។

កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា បានកំពុងជំរុញការចរចាជាមួយគណៈកម្មការសេដ្ឋកិច្ចអឺរ៉ាស៊ី ដើម្បីពង្រីកការបើកទីផ្សារកសិផលកម្ពុជាបន្ថែមទៀត រាប់ទាំងកៅស៊ូធម្មជាតិផងដែរ។ តាមតួលេខពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឱ្យដឹងថា កម្ពុជាបាននាំចេញជ័រកៅស៊ូចំនួន ១៣២ ១៧៤តោន ទៅកាន់ទីផ្សារក្រៅប្រទេសនៅក្នុងឆមាសទី ១ឆ្នាំ ២០២១នេះពោលគឺបានកើនឡើង ៧,១៨ភាគរយ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ cnc ចេញផ្សាយថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១។*

## លទ្ធផលសិក្សាស្រាវជ្រាវបង្ហាញថា ផលិតផលកសិកម្មកម្ពុជា ៩មុខ មានតម្លៃខ្ពស់លើទីផ្សារ




*ប្រភព ៖ SWIFT NEWS*

ក្រសួងពាណិជ្ជកម្មកម្ពុជា បានប្រកាសឱ្យដឹងពីលទ្ធផលសិក្សាស្រាវជ្រាវតាមរយៈកម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី(CAVAC) ស្តីពីផលិតផលកសិកម្មកម្ពុជាចំនួន៩មុខ ដែលមានតម្លៃខ្ពស់លើទីផ្សារ ដែលរួមមាន៖ ផ្លែស្វាយ មៀន ស្វាយចន្ទី ម្ទេស ដំឡូងជ្វា ផ្លែបឺរល្ងរ ស្ករត្នោត និងចេកក្រៀម ដែលអាចមានទីផ្សារប្រទេសអូស្ត្រាលី ណូវែលហ្សេឡង់ អឺរ៉ុប ចិន អាស៊ាន និងបណ្តាទីផ្សារសក្តានុពលផ្សេងទៀត។ ការប្រកាសនេះធ្វើឡើងក្រោមអធិបតីភាពរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឯកអគ្គរដ្ឋទូតនៃប្រទេសអូស្ត្រាលីប្រចាំកម្ពុជា និងដោយមានការចូលរួមពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនសំខាន់ៗផងដែរ។

ឯកអគ្គរដ្ឋទូតនៃប្រទេសអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានឱ្យតម្លៃលើវិស័យកសិកម្មកម្ពុជាថា ជាចំណុចកណ្តាលនៃការស្តារសេដ្ឋកិច្ចឡើងវិញ។ ការសិក្សារបស់ "CAVAC" លើផលិតផលកសិកម្មដែលមានតម្លៃខ្ពស់របស់កម្ពុជានេះ ជាមគ្គុទេសន៍ថ្មីមួយសម្រាប់ការរីកចម្រើននាពេលអនាគត តាមរយៈការលើកទឹកចិត្តវិស័យ

ឧស្សាហកម្ម ក្នុងការធ្វើពិពិធកម្មខ្សែសង្វាក់ផ្គត់ផ្គង់ការនាំចេញ ទៅជាប្រភេទដំណាំប្រកបដោយភាពច្នៃប្រឌិត ដូចជា ផ្លែប័រ និងគ្រាប់ស្វាយចន្ទី។ ទាំងនេះនឹងជួយធ្វើឱ្យវិស័យកសិកម្មមានភាពធន់ និងការប្រកួតប្រជែង។ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានស្នើក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនពាក់ព័ន្ធបន្តសហការឱ្យកាន់តែជិតស្និទ្ធបន្ថែមទៀត ជាពិសេសក្នុងការលើកកម្ពស់ផលិតកម្មផលិតផលកសិកម្មដែលមានតម្លៃខ្ពស់របស់កម្ពុជា ដើម្បីឈានទៅចាប់ទីផ្សារដែលមានសក្តានុពលក្នុងតំបន់ និងក្នុងពិភពលោក។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានជម្រាបអំពីសមិទ្ធផល និងផែនការការងារ ដែលក្រសួងពាណិជ្ជកម្មសម្រេចបាន និងកំពុងអនុវត្ត រួមមាន ការបញ្ចប់ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រួមមាន កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ ការងារអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ការងាររៀបចំយុទ្ធសាស្ត្រទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការងារអាទិភាពផ្សេងទៀត សំដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សេដ្ឋកិច្ចជាតិក្នុងអំឡុងពេលនិងបន្ទាប់ពីវិបត្តិកូវីដ-១៩៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ SWIFT NEWS ចេញផ្សាយថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០២១។*

## កម្ពុជាសង្ឃឹមថា ជើងហោះហើរផ្ទាល់ជាមួយជប៉ុននឹងចាប់ផ្តើមឡើងវិញឆាប់ៗ ខណៈក្រុមហ៊ុនអាកាសចរណ៍ជាង ១០ កំពុងដំណើការ




*ដោយ៖ អក្ខរា*

រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញក្តីសង្ឃឹមថា ក្រុមហ៊ុនអាកាសចរណ៍ ANA នឹងចាប់ផ្តើមការហោះហើរផ្ទាល់រវាងប្រទេសជប៉ុន និងកម្ពុជាឡើងវិញនាពេលឆាប់ៗខាងមុខ ដែលនឹងជួយជំរុញឱ្យទំហំពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរមានការកើនឡើង។

តាមតារាងហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍កម្ពុជា Cambodia Airports នៅក្នុងខែសីហា ឆ្នាំ២០២១នេះ មានក្រុមហ៊ុនអាកាសចរណ៍ជាង ១០ កំពុងដំណើរការហោះហើរ ពីរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ឆ្ពោះទៅប្រទេសចិន ហុងកុង សិង្ហបុរី និងវៀតណាមជាដើម។ ទោះយ៉ាងណា កាលវិភាគហោះហើរនាពេលបច្ចុប្បន្នអាចនឹងមានការប្រែប្រួលដោយសារតែការកែប្រែកម្មវិធីហោះហើរពីដៃគូក្រុមហ៊ុនអាកាសចរណ៍ផងដែរ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ SWIFT NEWS ចេញផ្សាយថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០២១។*

## រដ្ឋមន្ត្រីកសិកម្ម ណែនាំឱ្យកសិករចិញ្ចឹមត្រីអណ្តែង និងកង្កែបរួមគ្នា ចងក្រងជាបណ្តុំអាជីវកម្ម



ដោយ sopheak khoun

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និនេសាទ បានណែនាំដល់ប្រជាកសិករ ចិញ្ចឹមត្រី អណ្តែង និងកង្កែប ត្រូវសហការរួមគ្នាចងក្រងទៅជាបណ្តុំអាជីវកម្ម ឱ្យបានច្រើន ដើម្បីលើកកម្ពស់ទីផ្សារផលិតកម្មវារីវប្បកម្ម ឱ្យកាន់តែប្រសើរឡើង។ ការចងក្រងជាបណ្តុំអាជីវកម្ម ធ្វើឡើងដើម្បីជាកម្លាំងចលករផលិត កែច្នៃ ទីផ្សារ ទទួលបានព័ត៌មាន តម្លៃបន្ថែម ទទួលបានបច្ចេកទេស បង្កើតជាសំឡេងតវ៉ា អំពីផលប្រយោជន៍ផ្សេងៗ និងរួមគ្នាដោះស្រាយបញ្ហា។

ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តប៉ៃលិន បានលើកឡើងថា នៅខេត្តប៉ៃលិនមានបណ្តុំកង្កែប ចំនួន១២កន្លែង ស្មើនឹង២៧០គ្រួសារ មានកន្លែងបង្កាត់ និងភ្ញាស់កូនកង្កែប ១០កន្លែង ដែលអាចផលិតបាន ៣ម៉ឺនកូន និងមានបណ្តុំត្រី៥កន្លែង ស្មើនឹង៨៦គ្រួសារ ដែលអាចផលិតត្រីបាន១២តោន ក្នុងរយៈពេល៣ខែ។ ដោយឡែក កម្មវិធីផ្សព្វផ្សាយ បច្ចេកទេសកសិកម្មថ្មី ធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE) បានផ្តល់លទ្ធភាព ដល់កសិករក្នុងការទទួលផល ចិញ្ចឹមត្រី និងកង្កែបសរុបចំនួន ៤៦៨គ្រួសារ ក្នុងនោះស្ត្រី២០២ គ្រួសារ ដោយរៀបចំចងក្រងជាក្រុមបណ្តុំអាជីវកម្មត្រី និងកង្កែប ចំនួន១៧ បណ្តុំ។ ក្នុងនោះដែរ មានកសិករ ចំនួន៥គ្រួសារកំពុងដំណើរការចិញ្ចឹមបង្កងជាលក្ខណៈគ្រួសារ ដែលពីមុនៗមក មិនធ្លាប់មានឡើយ នៅក្នុងខេត្តប៉ៃលិន។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានណែនាំឱ្យមន្ត្រីជំនាញរដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋានត្រូវខិតខំចុះជួយ ជំរុញការចិញ្ចឹមត្រី និងកង្កែប ដាំបន្លែ ចិញ្ចឹមសត្វ ធ្វើយ៉ាងណាបង្កើនផលិតភាព ផលិតកម្មស្បៀង តាមរយៈការបង្កើនផលិតភាព ផលិតប្រែក្លាយវិបត្តិទៅជាឱកាសមាសដើម្បីពង្រីក និងពង្រឹងសមត្ថភាព ចិញ្ចឹមគ្រួសារតាមគ្រប់រូបភាព។ មន្ត្រីជំនាញរដ្ឋបាលជលផល ត្រូវបន្តចុះជួយផ្សព្វផ្សាយ បណ្តុះបណ្តាលបន្ថែម លើការងារបច្ចេកទេសចិញ្ចឹម បង្កាត់ ភ្ញាស់កូន វិធីលាយផ្សំចំណី ការថែទាំ ហើយត្រូវបង្កើនសកម្មភាព ចុះចែកកូនត្រី កូនកង្កែប និងតង់ចិញ្ចឹម ដល់គ្រួសារដែលចង់ពង្រីកអាជីវកម្មបន្ថែម និងអ្នកដែលចង់ចាប់ផ្តើមចិញ្ចឹម ហើយណែនាំគាត់ឱ្យចងក្រងបណ្តុំអាជីវកម្មព្រោះវាមានប្រយោជន៍។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏បានផ្តល់ជូនកសិករចិញ្ចឹមត្រីអណ្តែង ៣៥គ្រួសារ ដោយគ្រួសារនីមួយៗទទួលបានកូនត្រី ៧០០ក្បាល ចំណី ១០០គីឡូក្រាម និងតង់១។ ចំណែកកសិករចិញ្ចឹមកង្កែប ២៣គ្រួសារ ក្នុងមួយគ្រួសារ ទទួលបាន កូនកង្កែប៤០០ក្បាល ចំណី១០០គីឡូក្រាម និងតង់១ និងថ្នាំវីតាមីន ៣កញ្ចប់ និងកសិករផលិតកូនត្រីពូជ ចំនួន១ គ្រួសារផងដែរ។

គិតមកដល់ថ្ងៃនេះ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះចែកកូនត្រី កូនកង្កែប និងសម្ភារចិញ្ចឹម

បានចំនួន៧ខេត្ត រួមមាន៖ ខេត្តមណ្ឌលគីរី កំពង់ស្ពឺ កំពត ស្វាយរៀង ឧត្តរមានជ័យ ព្រះវិហារ និងខេត្តប៉ៃលិន ក្នុងចំណោមខេត្ត គោលដៅចំនួន១១ ដែលរួមមាន មណ្ឌលគីរី រតនគីរី កំពង់ស្ពឺ កំពត ស្វាយរៀង ប៉ៃលិន ត្បូងឃ្មុំ កណ្ដាល ព្រះសីហនុ ឧត្តរមានជ័យ និងព្រះវិហារ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ កម្ពុជាថ្មី ចេញផ្សាយថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២១។*

## តារាងប្រចាំសប្តាហ៍

### រូបភាពទី១៖ ការប្រៀបធៀបការអនុវត្តចំណូលថវិកាថ្នាក់ជាតិ ក្នុងខែមិថុនា ឆ្នាំ២០២១




រូបភាពទី១ ខាងលើនេះ បង្ហាញពីការប្រៀបធៀបការប្រមូលចំណូល ក្នុងខែមិថុនា ឆ្នាំ២០២១ ដែលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន។ ចំណូលក្នុងស្រុកសរុបមានចំនួនប្រមាណ ១ ៤២៧ ប៊ីលានរៀល ឬ ធ្លាក់ចុះជិត ២% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ដែលមានចំនួនជិត ១ ៤៥២ ប៊ីលានរៀល។ ក្នុងនោះ ចំណូលសារពើពន្ធអនុវត្តបាន៨% និងចំណូលមិនមែនសារពើពន្ធ អនុវត្តបានជិត ៥% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ឬ ធ្លាក់ចុះបន្តិចស្មើនឹង ១,១៨% និង ៤% រៀងគ្នា បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២០។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិប្រមូលចំណូលក្នុងស្រុកសរុប បានសម្រេចតាមផែនការគ្រោងដែលមានចំនួនប្រហែល ១០ ៥៧២ ប៊ីលានរៀល ឬ ស្មើនឹង ៥៣% នៃច្បាប់ឆ្នាំ២០២១ ខណៈដែលការអនុវត្តក្នុងរយៈពេលដូចគ្នា ឆ្នាំ២០២០ សម្រេចបានត្រឹមតែ ៤៦% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២០។ បើទោះបីជាវិបត្តិជំងឺកូវីដ-១៩ បាននឹងកំពុងបន្តដាក់សម្ពាធដល់ការប្រមូលចំណូលថវិកាជាតិក្នុងឆ្នាំ២០២១ ក៏ដោយក៏ការប្រមូលចំណូលថ្នាក់ជាតិនៅរក្សាបានស្ថិរភាពល្អ៕ ***ដោយ ឈន ហាំ***

*ប្រភព៖ ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១*

### រូបភាពទី២៖ ការប្រៀបធៀបការអនុវត្តចំណាយថវិកាថ្នាក់ជាតិ ខែមិថុនា ឆ្នាំ២០២១



រូបភាពទី២ ខាងលើនេះ បង្ហាញពីការប្រៀបធៀបការអនុវត្តចំណាយថវិកា ក្នុងខែមិថុនា ឆ្នាំ២០២១ ដែលរដ្ឋបាលថ្នាក់ជាតិអនុវត្តបាន។ ចំណាយសរុបថ្នាក់ជាតិមានចំនួនប្រមាណ ២ ០៣៩ ប៊ីលានរៀល ឬ ធ្លាក់ចុះ ២៨% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ដែលមានចំនួនប្រហែល ២ ៧៩៦ ប៊ីលានរៀល។ ការថយចុះនេះ ដោយសារការរឹងបន្តឹងចំណាយមិនចាំបាច់ និងការបង្វែរមុខសញ្ញាអនុវត្តឱ្យចំគោលដៅ ប្រកបដោយបុរេសកម្ម សំដៅបន្តដោះស្រាយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

ក្នុងខែមិថុនា ឆ្នាំ២០២១ ចំណាយសរុបថ្នាក់ជាតិដែលសម្រេចបាន ២ ០៣៩ ប៊ីលានរៀល ស្មើនឹងជិត ៧% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១។ ក្នុងនោះ ចំណាយចរន្តអនុវត្តបាន ១ ២៨៧ ប៊ីលានរៀល និងចំណាយមូលធនអនុវត្តបានជិត ៧៥២ ប៊ីលានរៀល។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិ បានអនុវត្តការចំណាយសរុបថ្នាក់ជាតិ សម្រេចបានចំនួនប្រហែល ១១ ១៦១ ប៊ីលានរៀល ឬស្មើនឹង ៣៨% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២១ ដែលសម្រេចបានទាបជាងផែនការគ្រោង៕ *ដោយ ឈន ហាំ*

*ប្រភព៖ ការអនុវត្តថវិការដ្ឋ ខែធ្នូ ឆ្នាំ២០២០ និងការអនុវត្តថវិការដ្ឋ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### អតិរេកពាណិជ្ជកម្មឥណ្ឌូណេស៊ី សម្រាប់ខែកក្កដា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

យោងតាមស្ថិតិឥណ្ឌូណេស៊ី (BPS) បានបង្ហាញថា ឥណ្ឌូណេស៊ីមានអតិរេកពាណិជ្ជកម្មចំនួន២,៥៩ ពាន់លានដុល្លារអាមេរិក នៅក្នុងខែកក្កដា ឆ្នាំ២០២១ ធៀបនឹងខែមុន ដែលមានត្រឹមតែ ១,៣២ ពាន់លានដុល្លារអាមេរិក។ ការរួមចំណែកដ៏ធំបំផុតនៃអតិរេកនៅក្នុងខែ កក្កដា ឆ្នាំ ២០២១ គឺការនាំចេញសត្វ ឬបន្លែ ខ្លាញ់និងប្រេងឥន្ទនៈ រ៉ែដែក និងដែកថែប នេះបើតាមបញ្ជាក់របស់ប្រធាន ទីភ្នាក់ងារស្ថិតិកណ្ដាល (BPS) លោក Margo Yuwono។

ឥណ្ឌូណេស៊ីមានអតិរេកពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិកចំនួន ១,២៧ ពាន់លានដុល្លារ ជាមួយប្រទេសហ្វីលីពីន ចំនួន ៥៣៣ លានដុល្លារ និងជាមួយប្រទេសម៉ាឡេស៊ី ៣៩៧,៥ លានដុល្លារ ។
ទោះយ៉ាងណា ឥណ្ឌូនេស៊ីក៏មានឱនភាពពាណិជ្ជកម្មជាមួយប្រទេសមួយចំនួនផងដែរ ដូចជា ប្រទេសចិន (៨៤៤,៥ លានដុល្លារ) ប្រទេសអូស្ត្រាលី (៤៤៨,១ លានដុល្លារ) និងប្រទេសថៃ (២៧១,១ លានដុល្លារ)៕ *ដោយ ជឹម ប៊ុនធឿន*

| | មិថុនា ឆ្នាំ២០២១ | កក្កដា ឆ្នាំ២០២១ |
|---|---|---|
| ការនាំចេញ | 18.55 | 17.70 |
| ការនាំចូល | 17.23 | 15.11 |
| តុល្យភាពពាណិជ្ជកម្ម | 1.32 | 2.59 |

*ប្រភព៖ Central Bureau of Statistics (bps.go.id)*

## ឱនភាពពាណិជ្ជកម្មវៀតណាម សម្រាប់ពាក់កណ្ដាលខែដំបូង នៃខែកក្កដា ឆ្នាំ២០២១ (គិតជាពាន់លានដុល្លារ)

យោងតាមស្ថិតិគយប្រទេសវៀតណាមបានបង្ហាញថា ការនាំចេញសរុបរបស់ប្រទេសវៀតណាម នៅពាក់កណ្ដាលខែដំបូង នៃខែកក្កដា មានចំនួន ១២,៧៨ ពាន់លានដុល្លារ ខណៈការនាំចូលមានចំនួន១៤,៦១ ពាន់លានដុល្លារ។ ដូច្នេះ ប្រទេសវៀតណាម មានឱនភាពពាណិជ្ជកម្មចំនួន ១,៨៣ ពាន់លានដុល្លារ សម្រាប់រយៈពេលពាក់កណ្ដាលខែដំបូង នៃខែកក្កដា ឆ្នាំ២០២១។

បើធៀបទៅនឹងរយៈពេលពាក់កណ្ដាលខែដំបូង នៃខែកក្កដា ឆ្នាំ២០២១ ការនាំចេញថយចុះ ១៣,៩% ស្មើ ២,០៦ ពាន់លានដុល្លារ។ ការថយចុះនេះ មានការចូលរួមពីទូរស័ព្ទចល័ត និងគ្រឿងបន្លាស់ទូរស័ព្ទចំនួន៣៩% ស្មើ ៦២៩,៤២ លានដុល្លារ កុំព្យូទ័រ និងផលិតផលអគ្គិសនីចំនួន ៣៥% ស្មើ ៥៦៥,៣៥ លានដុល្លារ ផលិតផលស្បែកជើង (Foot-wears) ចំនួន ១៥% ស្មើ ១២៧,២៤ លានដុល្លារ ផលិតផលធ្វើពីឈើនិងឈើចំនួន ១៨% ស្មើ ១២៣,៦៥ លានដុល្លារ ផលិតផលប្រេងចំនួន ១៥៨% ស្មើ ៥០,៤៩ លានដុល្លារ ប្រេងឆៅចំនួន ១៣៩% ស្មើ ៣៨,៤២ លានដុល្លារ។

ដោយឡែក ការនាំចូលបានកើនឡើង ៤,៨% ធៀបទៅនឹងពាក់កណ្ដាលខែដំបូង នៃខែមិថុនា ឆ្នាំ២០២១ ដែលឆ្លុះបញ្ចាំងពីការកើនឡើងនៃម៉ាស៊ីន គ្រឿងបរិក្ខា និងឧបករណ៍មានចំនួន ៧% ស្មើ ១៤៥,២៣ លានដុល្លារ ពោតមានចំនួន ៤៣% ស្មើ ៧៤,៦០ លានដុល្លារ និងផលិតផលប្រេងមានចំនួន ១៦% ស្មើ ៣៣,២៩ លានដុល្លារ ។ *ដោយ ជឹម ប៊ុនធឿន*

| | ទំហំជួញដូរ | កំណើន (%) |
|---|---|---|
| **ការនាំចេញ** | ១២,៧៨ | -១៣,៩ |
| **ការនាំចូល** | ១៤,៦១ | ៤,៨ |
| **តុល្យភាពពាណិជ្ជកម្ម** | -១,៨៣ | - |

*ប្រភព៖ Vietnam Customs*

## អតិផរណា នៅប្រទេសហ្វីលីពីនទំនងជាមានភាពលើសពីគោលដៅដែលរដ្ឋាភិបាលកំណត់ម្ដងទៀតនៅខែសីហា



*ប្រភព៖philstar.2021 រូបភាព៖ The STAR / Michael Varcas*

យោងតាមកាសែត Bangko Sentral ng Pilipinas (BSP) ថ្លៃឧស្ម័នប្រេងឥន្ធនៈដែលមានជាតិពុលខ្ពស់ និងថ្លៃដើមអគ្គិសនីទំនងជាជំរុញឱ្យអតិផរណាហួសពីគោលដៅរបស់រដ្ឋាភិបាលម្ដងទៀតនៅខែសីហា បើទោះ បីជា ទំនិញម្ហូបអាហារមានតម្លៃថោកជាងមុនក៏ដោយ។

នៅក្នុងសេចក្ដីថ្លែងការណ៍បានបង្ហាញថា៖ តម្លៃទំនិញអ្នកប្រើប្រាស់ ត្រូវបានរំពឹងថានឹងមានកំណើនចន្លោះពី ៤,១ទៅ៤,៩% ក្នុងខែសីហា។ ក្នុងពេលជាមួយគ្នានេះការព្យាករណ៍របស់BSP បានបង្ហាញថាអតិផរណាអាចលើសគោលដៅប្រចាំឆ្នាំ ២%ទៅ ៤% របស់រដ្ឋាភិបាលម្ដងទៀត។ អាជ្ញាធរស្ថិតិហ្វីលីពីន

នឹងបញ្ចេញទិន្នន័យអតិផរណាផ្លូវការសម្រាប់ខែសីហា នៅថ្ងៃទី ៧ ខែកញ្ញា។

ទន្ទឹមនឹងនេះ ធនាគារកណ្ដាលបានលើកឡើងផងដែរពីការឡើងថ្លៃភាគច្រើនបានមកពីតម្លៃខ្ពស់នៃឧស្ម័នធម្មជាតិ LPG ដែលកើនឡើងចំនួន ៣៦ប៉េសូ ក្នុងធុងចំណុះ ១១ គីឡូក្រាម កាលពីខែសីហា ដោយផ្អែកលើទិន្នន័យរបស់នាយកដ្ឋានថាមពល។ ការកែតម្រូវអត្រា ពីក្រុមហ៊ុនម៉ានីឡាអេឡិចត្រូនិកដែលជាអ្នកចែកចាយថាមពលធំបំផុតរបស់ប្រទេសក៏បានបន្ថែមសម្ពាធតម្លៃកើនឡើងខ្លះនៅខែនេះ។ ការកើនឡើងលើថ្លៃបញ្ជូនខ្ពស់បានបង្កើនអត្រាររួមរបស់ Meralco's ចំនួន ០,០៩៦៥ ក្នុងមួយគីឡូវ៉ាត់ម៉ោងក្នុងខែសីហា ដែលមានន័យថាកើនឡើងប្រហែល ១៩ប៉េសូ ក្នុងវិក្កយបត្រសរុបរបស់គ្រួសារដែលមានការប្រើប្រាស់ជាមធ្យម ២០០ គីឡូវ៉ាត់ម៉ោង។

ការឡើងចុះតម្លៃប្រេងឥន្ធនៈគឺជាតម្លៃប្រេងឥន្ធនៈក្នុងស្រុក។ ទិន្នន័យរបស់នាយកដ្ឋានថាមពលបានបង្ហាញថាក្រុមហ៊ុនប្រេងក្នុងស្រុកបានធ្វើការកែតម្រូវតម្លៃចំនួនបួននៅក្នុងខែសីហា ដែលចំនួនបីគឺជាការធ្លាក់ចុះ។ ធនាគារកណ្ដាលបាននិយាយថាតម្លៃអង្ករក៏ធ្លាក់ចុះដែរក្នុងខែនេះ។

អ្នកសេដ្ឋកិច្ចវិទូរំពឹងថាអតិផរណានឹងបន្តកើនឡើងពេញមួយឆ្នាំដោយលើកឡើងពីព្យុះទីហ្វុងនិងបញ្ហាការដឹកជញ្ជូននាពេលខាងមុខដោយសារតែការបិទទ្វារដែលអាចបង្កើតសម្ពាធតម្លៃកើនឡើងនៅប៉ុន្មានខែខាងមុខនេះ។ ប្រាក់ប៉េសូមានភាពទន់ខ្សោយដែលធ្វើឱ្យការនាំចូលថ្លៃជាងមុនក៏ជាកត្តាជំរុញកំណើនតម្លៃលឿនផងដែរ។ ប៉ុន្តែខណៈអតិផរណាអាចស្ថិតនៅលើសគោលដៅក្នុងឆ្នាំនេះរដ្ឋាភិបាលប្ដេជ្ញារក្សាគោលនយោបាយរូបិយវត្ថុដែលមានភាពធូររលុងបំផុតរបស់ធនាគារកណ្ដាលដរាបណាវាអាចជួយដល់សេដ្ឋកិច្ចដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាតនេះ។ *ដោយ សេន ចន្ទី*

*ប្រភព៖ philstar. ចេញផ្សាយថ្ងៃទី៣១ខែសីហា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### តម្លៃប្រេងឆៅធ្លាក់ចុះ ខណៈរោងចក្រចម្រាញ់ប្រេងអាមេរិកបិទទ្វារ ដោយសាររងការខូចខាតពីព្យុះសង្ឃរា Ida



*ប្រភព៖ CNA ២០២១, រូបភាព៖ REUTERS/Jonathan Alcorn*

តម្លៃប្រេងឆៅ បានធ្លាក់ចុះនៅថ្ងៃអង្គារសប្ដាហ៍នេះ ដោយសារការព្រួយបារម្ភពីការដាច់ចរន្តអគ្គិសនី និងការជន់លិចដោយទឹកជំនន់នៅរដ្ឋ Louisiana បន្ទាប់ពីរងការវាយប្រហារពីព្យុះសង្ឃរា Ida ដែលនឹងកាត់បន្ថយតម្រូវការប្រេងឆៅពីរោងចក្រចម្រាញ់ប្រេងរបស់សហរដ្ឋអាមេរិក ស្របពេលដែលក្រុមហ៊ុនផលិតប្រេងសកល គ្រោងបង្កើនទិន្នផលប្រេង។

ជាក់ស្ដែង តម្លៃប្រេងឆៅរបស់សហរដ្ឋអាមេរិក West Texas Intermediate (WTI) បានធ្លាក់ចុះ ៤១សេន ឬ ០,៦% មកនៅត្រឹម ៦៨,៨០ដុល្លារអាមេរិក ក្នុងមួយ

បារ៉ែល គិតត្រឹមម៉ោង ០២៖៤៥ព្រឹក ម៉ោងសកល ដែលបានផ្លាស់ប្តូរពីការកើនឡើងនៃតម្លៃប្រេងយ៉ាងខ្លាំង កាលពីថ្ងៃចន្ទ។ ចំណែកឯ តម្លៃប្រេងឆៅ Brent របស់អង់គ្លេស សម្រាប់ខែតុលា ឆ្នាំ២០២១ ដែលនឹងផុតកំណត់នៅថ្ងៃអង្គារសប្តាហ៍នេះ បានធ្លាក់ចុះ ៤៦សេន ឬ ០,៦% មកនៅត្រឹម ៧២,៩៥ដុល្លារអាមេរិក ក្នុងមួយបារ៉ែល បន្ទាប់ពីកើនឡើងជិត ១% កាលពីថ្ងៃចន្ទ។ ជាមួយគ្នានេះដែរ តម្លៃប្រេងឆៅក្នុងកិច្ចសន្យា សម្រាប់ខែវិច្ឆិកា ឆ្នាំ២០២១ បានធ្លាក់ចុះ ៤២សេន ឬ ០,៦% មកនៅត្រឹម ៧១,៨១ដុល្លារអាមេរិក ក្នុងមួយបារ៉ែល។

ទន្ទឹមនឹងនេះ ការរំពឹងទុកនូវការពន្យារពេលនៃការបិទទ្វាររោងចក្រចម្រាញ់ប្រេង នឹងប៉ះពាល់ដល់តម្រូវការប្រេង ព្រមទាំងដាក់សម្ពាធតម្លៃប្រេង ខណៈ រោងចក្រផលិតប្រេងនៅប៉ែកឈូងសមុទ្រម៉ិកស៊ិករបស់សហរដ្ឋអាមេរិក ដែលអាចផលិតប្រេងឆៅប្រហែល ១,៧២លានបារ៉ែលក្នុងមួយថ្ងៃ នៅបិទដំណើរការនៅឡើយ ដោយសាររោងចក្របានជម្លៀសកន្លែងផលិតប្រេងចេញមុនការវាយប្រហារនៃព្យុះសង្ឃរា Ida។ ក្រុមហ៊ុនរំពឹងថានឹងចំណាយពេលច្រើនថ្ងៃ ដើម្បីធ្វើការវាយតម្លៃពេញលេញអំពីការខូចខាតដែលអាចកើតមានឡើង។

យ៉ាងណាមិញ ការរក្សាតម្លៃប្រេង គឺជាការរំពឹងទុកដែលអង្គការនៃប្រទេសនាំចេញប្រេង និងសម្ព័ន្ធមិត្តរបស់ខ្លួន ដែលត្រូវបានគេស្គាល់ថាជាអង្គការ OPEC+ នឹងយល់ព្រមបន្តផែនការបន្ថែមការផ្គត់ផ្គង់ប្រេងចំនួន ៤០០ ០០០បារ៉ែលក្នុងមួយថ្ងៃ ជារៀងរាល់ខែ រហូតដល់ខែធ្នូ ឆ្នាំ២០២១។

សូមបញ្ជាក់ដែរថា សមាជិកនៃអង្គការ OPEC+ នឹងជួបពិភាក្សាអំពីការកំណត់ទិន្នផលប្រេងនៅថ្ងៃពុធសប្តាហ៍នេះ។ ពួកគេរំពឹងថា ការកើនឡើងនៃការផលិតប្រេងនឹងដំណើរការទៅមុខ។ ទោះយ៉ាងណា រដ្ឋមន្ត្រីប្រេងរបស់ប្រទេសគុយវ៉ែត បានមានប្រសាសន៍ថា ផែនការនេះអាចត្រូវបានពិចារណាឡើងវិញ ដោយសារមានការព្រួយបារម្ភអំពីការផ្ទុះឡើងនៃជំងឺកូវីដ-១៩ នៅអាស៊ី ដែលអាចកំណត់តម្រូវការប្រេង៕ *ដោយ ស៊ិន សុភាព៌*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Channel New Asia ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១*

## អតិផរណានៅប្រទេសបារាំង កើនឡើងខ្ពស់ជាងការរំពឹងទុកក្នុងខែសីហា ឆ្នាំ២០២១ ដែលជាកម្រិតខ្ពស់បំផុតក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ




*ប្រភព៖ Reuters ២០២១, រូបភាព៖ REUTERS/Stephane Mahe*

អតិផរណានៅប្រទេសបារាំង បានកើនឡើងលើសពីការរំពឹងទុកនៅក្នុងខែសីហា ឆ្នាំ២០២១ ក្នុងអត្រាលឿនបំផុតក្នុងរយៈពេលជិត ៣ឆ្នាំ នេះបើយោងតាម

ការប៉ាន់ស្មានបឋមផ្លូវការពីទីភ្នាក់ងារស្ថិតិ INSEE ដែលទើបបានចេញផ្សាយកាលពីថ្ងៃអង្គារសប្ដាហ៍នេះ។

សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ដែលចុះសម្រុងគ្នារបស់សហភាពអឺរ៉ុប បានកើនឡើង ០,៧% ក្នុងខែសីហា ពីខែកក្កដា ឆ្នាំ២០២១ ជាមួយនឹងអត្រា ២,៤% ប្រចាំឆ្នាំ កើនពី ១,៥% ក្នុងខែកក្កដា ឆ្នាំ២០២១ ដែលជាអត្រាអតិផរណាខ្ពស់បំផុតក្នុងរយៈពេល ១២ខែ ចាប់តាំងពីខែតុលា ឆ្នាំ២០១៨។

ការកើនឡើងនេះ គឺលើសពីការរំពឹងទុករបស់ក្រុមសេដ្ឋវិទូចំនួន ១៦រូប ដែលស្ទង់មតិដោយ Reuters ដែលមានត្រឹម ២,១% ប៉ុណ្ណោះ ខណៈដែលការព្យាករណ៍ខ្ពស់បំផុតគឺ ២,២%។

ទោះយ៉ាងណា លោក Francois Villeroy de Galhau ទេសាភិបាលធនាគារកណ្ដាលបារាំង បានមានប្រសាសន៍ថា បើទោះបីជាការរឹតបន្តឹងសង្វាក់ផ្គត់ផ្គង់នឹងជំរុញឱ្យមានអតិផរណាក្នុងរយៈពេលខ្លីក៏ដោយ ក៏លោកនៅតែរំពឹងថាការកើនឡើងនេះ គឺគ្រាន់តែជាការកើនឡើងបណ្ដោះអាសន្នប៉ុណ្ណោះ៕ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Reuters ចុះថ្ងៃទី៣១ខែសីហា ឆ្នាំ២០២១*

## មហាអំណាចសេដ្ឋកិច្ចចិន សម្រេចកាត់បន្ថយការនាំចូលគ្រឿងសមុទ្រពី វៀតណាម ដោយសារកូវីដ១៩



*រូបភាព៖ ងួន សុក័ត្រា*

មហាអំណាចសេដ្ឋកិច្ចចិន បានសម្រេចកាត់បន្ថយការនាំចូលគ្រឿងសមុទ្រពី វៀតណាម ដោយសារបញ្ហាកូវីដ១៩។ ការរឹតបន្តឹងលក្ខខណ្ឌនាំចូលជាច្រើនបានបន្តជាការលំបាកដល់ វិស័យជលផលរបស់វៀតណាម។ នៅក្នុងរយៈពេល ៧ខែ ដើមឆ្នាំ ២០២១នេះ ការនាំចេញគ្រឿងសមុទ្រពី វៀតណាម ទៅកាន់ប្រទេសចិន មានការធ្លាក់ចុះជាង ៥% ធៀបនឹងពេលដូចគ្នាកាលពីឆ្នាំមុន។

បញ្ហាចម្បង កើតមានឡើងនៅចន្លោះថ្ងៃទី ២០ ខែមិថុនា ដល់ថ្ងៃទី ១៥ ខែកក្កដា ដែលតំបន់ពាណិជ្ជកម្មដ៏ធំបំផុតមួយរបស់ចិន គឺតំបន់ហ្សង់ជាំង បានសម្រេចហាមឃាត់ការនាំចូលគ្រឿងសមុទ្រកក ពីបណ្ដាប្រទេសចំនួន១១ ដែលរួមមានទាំង ឥណ្ឌា វៀតណាម និងថៃ ដោយសារតែបញ្ហាមេរោគកូវីដ១៩។

លើសពីនេះ ការនាំចេញត្រីប្រាពីវៀតណាម ទៅកាន់ប្រទេសចិន ក៏មានការធ្លាក់ចុះ ដោយក្នុងត្រីមាសទី ២ បានធ្លាក់ចុះ ១១% ហើយនៅក្នុងត្រីមាសទី ៣

នេះ អាចនឹងបន្តការធ្លាក់ចុះទៀត ដែលប៉ះពាល់ក្រុមហ៊ុនវៀតណាមជាង ១០០ក្រុមហ៊ុន។

សមាគមអ្នកផលិត និងនាំចេញគ្រឿងសមុទ្រវៀតណាម អះអាងថា ទោះបីជា ចិន មានតម្រូវការផលិតផលគ្រឿងសមុទ្រវៀតណាមច្រើនក៏ដោយ រដ្ឋាភិបាលចិននៅតែចាត់វិធានការក្តៅ រឹតបន្តឹងគ្រប់លក្ខខណ្ឌនៃការនាំចូល ហើយជាពិសេស ប្រជាជនចិន ចាប់ផ្តើមងាកទៅប្រើប្រាស់ផលិតផលក្នុងស្រុកវិញ ដែលធ្វើឲ្យរដ្ឋាភិបាលចិន កាន់តែរឹតបន្តឹងលើការនាំចូល។

បន្ថែមលើនេះ ចិនក៏បានរឹតបន្តឹងលើការនាំចូលផលិតផលកសិកម្មពីប្រទេសវៀតណាម នៅតាមតំបន់ពាណិជ្ជកម្មតាមព្រំដែន ដូចជា ខេត្តយូណានប្រទេសចិន បានផ្អាកនាំចូលផលិតផលកសិកម្មវៀតណាមជាង ១ខែទៅហើយ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ pnn ចេញផ្សាយថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី០៦ ខែកញ្ញា ឆ្នាំ២០២១

- IHS Markit Eurozone Construction PMI បានធ្លាក់ចុះមកនៅត្រឹម ៤៩,៨ ក្នុងខែកក្កដា ឆ្នាំ ២០២១
- ការធ្លាក់ចុះ ការចុះបញ្ជីរថយន្តថ្មីនៅចក្រភពអង់គ្លេស ២៩,៥% ក្នុងខែកក្កដាឆ្នាំ ២០២១

ថ្ងៃអង្គារ ទី០៧ ខែកញ្ញា ឆ្នាំ២០២១

- ទុនបំរុងរូបិយប័ណ្ណបរទេស នៅប្រទេសជប៉ុនបានកើនឡើងដល់ ១ ៣៨៦ ៥០០ លានដុល្លារក្នុងខែកក្កដា
- កំណើននៃការនាំចេញពីប្រទេសចិនបានកើនឡើង ១៩,៣% នៅខែកក្កដាឆ្នាំ ២០២១

ថ្ងៃពុធ ទី០៨ ខែកញ្ញា ឆ្នាំ២០២១

- សេដ្ឋកិច្ចជប៉ុនបានកើនឡើង ១,៣% នៅក្នុងត្រីមាសទី ២
- កំណើនផលិតកម្មឧស្សាហកម្ម នៅប្រទេសអាហ្សង់ទីន

ថ្ងៃព្រហស្បតិ៍ ទី០៩ ខែកញ្ញា ឆ្នាំ២០២១

- អត្រាអតិផរណាប្រចាំឆ្នាំរបស់ប្រទេសចិនបានធ្លាក់ចុះមកនៅត្រឹម ១,០% ក្នុងខែកក្កដាឆ្នាំ ២០២១
- អតិរេកពាណិជ្ជកម្មរបស់ប្រទេសអាល្លឺម៉ង់បានកើនឡើងដល់ ១៦,៣ ពាន់លានអឺរ៉ូនៅខែមិថុនាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី១០ ខែកញ្ញា ឆ្នាំ២០២១

- កំណើន ផលិតផលក្នុងស្រុកសរុបរបស់ចក្រភពអង់គ្លេសបានកើនឡើង ៤,៨% ភាគរយនៅត្រីមាសទី ៣ ក្នុងរយៈពេល ៣ ខែដល់ខែមិថុនាឆ្នាំ ២០២១
- សេដ្ឋកិច្ចកាណាដា បានបង្កើតការងារចំនួន ៩៤ ពាន់នៅខែកក្កដាឆ្នាំ ២០២១៕